**សលាកប័ត្រព័ត៌មាន៖** ការតវ៉ារបស់កម្មករប្រមូលសំរាមក្រុមហ៊ុនស៊ីនទ្រី
**ពេលវេលា៖** ខែកុម្ភៈ ឆ្នាំ២០១៤
**ទិដ្ឋភាពរួម៖** ការតវ៉ារបស់កម្មករប្រមូលសំរាមនាពេលថ្មីៗ និងការចរចារជាបន្តបន្ទាប់ជាមួយនឹងក្រុមហ៊ុនស៊ីនទ្រី បានបង្ហាញពីភាពអត់ធ្មត់របស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល" និងគូសបញ្ជាក់សកម្មភាពនៃការធ្វើកូដកម្មដោយសមូហវិធី អាចត្រូវបានដោះស្រាយដោយសន្តិវិធីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") តាមរយៈកិច្ចសន្ទនា និងការសម្រុះសម្រួលរវាងភាគីទាំងអស់។

## សេចក្តីផ្តើម

នៅក្នុងបរិបទនៃការកើនឡើងនូវបាតុកម្ម និងកូដកម្មរបស់កម្មករ ក្នុងការទាមទារប្រាក់ឈ្នួល និងលក្ខខណ្ឌការងារឲ្យកាន់តែប្រសើរ សលាកប័ត្រព័ត៌មាននេះ ផ្តល់ជូននូវទិដ្ឋភាពទូទៅនៃការតវ៉ារបស់កម្មករប្រមូលសំរាមនាពេលថ្មីៗនេះ និងការចរចារជាបន្តបន្ទាប់ជាមួយនឹងក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី។ កូដកម្មទាមទារបង្កើនប្រាក់ឈ្នួលអប្បបរមា និងលើកកម្ពស់លក្ខខណ្ឌការងារ បានប្រព្រឹត្តទៅ ថ្វីបើមានបម្រាមចុងក្រោយរបស់រដ្ឋាភិបាលក្នុងការហាមឃាត់ការធ្វើបាតុកម្ម ការប្រមូលផ្តុំ និងការដើរហែក្បួនគ្រប់ប្រភេទ ហើយការធ្វើកូដកម្មនេះបានធ្វើទៅដោយសន្តិវិធី បើទោះជាមានវត្តមានកងរាជអាវុធហត្ថជាច្រើននាក់យ៉ាងណាក្តី។ ការតវ៉ានេះធ្វើឡើងជោគជ័យមួយផ្នែក ដោយហេតុថានៅក្នុងអំឡុងពេលនៃការចរចារ ក៏មានការសម្រុះសម្រួលរវាងគ្នានឹងគ្នា ហើយក្រុមហ៊ុនស៊ីនទ្រីបានយល់ព្រមទៅនឹងការទាមទារជាក់លាក់មួយចំនួន ដែលជាសញ្ញាណនៃការបិទបញ្ចប់ការធ្វើកូដកម្មផងដែរ។

សលាកប័ត្រព័ត៌មាននេះ តាក់តែងឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## សាវតារនៃករណី

កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៤ កម្មករប្រមាណជាង ១.០០០ នាក់ ក្នុងចំណោមកម្មករសរុប ១.៤០០ នាក់ ដែលបម្រើការឲ្យក្រុមហ៊ុនស៊ីនទ្រី បានធ្វើកូដកម្ម ដើម្បីទាមទារឲ្យមានការតំឡើងប្រាក់ឈ្នួល និងលក្ខខណ្ឌការងារឲ្យកាន់តែប្រសើរ។ ក្នុងអំឡុងនៃការចរចារ កម្មករបានលើកឡើងពីការទាមទារចំនួន ៩ ចំណុច ដែលរួមទាំងការទាមទារប្រាក់ឈ្នួលអប្បបរមាចំនួន ១៥០ ដុល្លារក្នុង១ខែសម្រាប់កម្មករប្រមូលសំរាម ប្រាក់ឧបត្ថម្ភផ្នែកសុខភាព និងកម្រៃលើការងារថែមម៉ោងដែលបានបំពេញនៅថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកសម្រាប់បុណ្យជាតិ។ ក្រុមហ៊ុនស៊ីនទ្រី ដែលជាសាខាមួយនៃសហគ្រាសកាណាដា ដែលមានឈ្មោះថា ស៊ីនទ្រែក ទទួលបាននូវសិទ្ធិផ្តាច់មុខលើការប្រមូល និងចោលសំរាមនៅក្នុងរាជធានីភ្នំពេញចាប់តាំងពីឆ្នាំ២០០២ បន្ទាប់ពីបានចុះកិច្ចព្រមព្រៀងរយៈពេល ៤៩ ឆ្នាំជាមួយនឹងរដ្ឋាភិបាល។ មុនពេលធ្វើកូដកម្ម កម្មករប្រមូល

សំរាម រកប្រាក់បានចំនួន ៦៥ ដុល្លារក្នុង១ខែ ជាងជួសជុល និងអ្នកបើកឡានទទួលបានចំនួន ១១០ ដុល្លារក្នុង ១ខែ ហើយអ្នកបើកឡានដឹកសំរាមពេលយប់ទទួលបានចំនួន ១២០ ដុល្លារក្នុង១ខែ។ ពុំមានកម្មករណាម្នាក់ទទួលបានការតំឡើងប្រាក់ឈ្នួលនៅក្នុងរយៈពេលប្រមាណ ១០ ឆ្នាំនេះទេ។

ជាការឆ្លើយតបទៅនឹងសំណើររបស់កម្មករ និងការចរចារដំបូងជាមួយនឹងមេដឹកនាំសហជីព និងតំណាងក្រុមហ៊ុន ក្រុមហ៊ុនស៊ីនទ្រី បានអះអាងថា ការតំឡើងប្រាក់ឈ្នួលឲ្យទៅកម្មករប្រមូលសំរាមច្រើនជាង ៨០ ដុល្លារក្នុង១ខែ អាចនឹងជះឥទ្ធិពលមិនល្អដល់ក្រុមហ៊ុន។ ការចរចារបានបរាជ័យ ហើយមេដឹកនាំសហជីពបានច្រានចោលភ្លាមៗចំពោះការតំឡើងចំនួន ១៥ ដុល្លារក្នុង១ខែ ដែល ក្រុមហ៊ុនស៊ីនទ្រីបានផ្តល់ជូនកាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៤។ លោក មុំ សារ៉ែន ដែលជាប្រធានសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ បានចូលរួមធ្វើជាអ្នកតំណាងឲ្យកម្មករទាំងនោះក្នុងអំឡុងពេលចរចារ។ កម្មករត្រូវបានដាក់សម្ពាធឲ្យទទួលយកនូវការសម្រុះសម្រួល បន្ទាប់ពីកម្មករទាំងនោះត្រូវអគ្គនាយកស្តីទីរបស់ក្រុមហ៊ុនស៊ីនទ្រី លោក សេង ចំរើន និងអភិបាលរងរាជធានីភ្នំពេញ លោក ខួង ស្រេង គំរាមកំហែងជាសាធារណៈដោយបាននិយាយថា អាជ្ញាធរនឹងចាត់វិធានការ ប្រសិនបើការតវ៉ានេះនៅតែបន្ត។

កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ ព្រឹត្តិការណ៍នៃការតវ៉ាបានក្លាយទៅជាបញ្ហាដែលត្រូវតែដោះស្រាយជាបន្ទាន់។ កងរាជអាវុធហត្ថ នគរបាលបង្ក្រាបកុបកម្ម និងសន្តិសុខឯកជន ត្រូវបានដាក់ពង្រាយនៅចំពោះការតវ៉ាដោយសន្តិវិធីរបស់កម្មករក្រុមហ៊ុនស៊ីនទ្រីនៅម៉ោង ៩ ព្រឹក។ ទោះបីជាមានវត្តមាននគរបាលដ៏លើសលុប ការតវ៉ានៅតែបន្តដោយអហិង្សាដដែល។ នៅវេលាម៉ោង ២ រសៀល បន្ទាប់ពីការចរចារអស់ជាច្រើនម៉ោងរួចមក កម្មករបានយល់ព្រមទទួលយកការតំឡើងប្រាក់ឈ្នួលពី ២០ ដុល្លារ ទៅ ២៥ ដុល្លារ ក្នុង១ខែ ដោយអាស្រ័យលើប្រភេទនៃសកម្មភាពការងារ ហើយដែលនឹងត្រូវអនុវត្តចាប់ពីខែមីនា ហេតុដូចនេះ កម្មករប្រមូលសំរាមនឹងទទួលបានការតំឡើងប្រាក់ឈ្នួលពី ៦៥ ដុល្លារ ទៅដល់ ៩០ ដុល្លារក្នុង១ខែ ហើយអ្នកបើកឡានដឹកសំរាមពេលយប់នឹងទទួលបានការតំឡើងពី ១២០ ដុល្លារ ទៅដល់ ១៤០ ដុល្លារក្នុង១ខែ។ សម្បទានផ្សេងៗទៀតដែលក្រុមហ៊ុនស៊ីនទ្រីបានធ្វើរួមមានការឈប់កាត់ប្រាក់ឈ្នួលរបស់កម្មករសម្រាប់ថ្លៃឯកសណ្ឋាន និងការព្រមព្រៀងឲ្យមានការផ្តល់សេវាកម្មសុខភាពរយៈពេល ២៤ ម៉ោងសម្រាប់បម្រើឲ្យកម្មករ។ ទោះបីជាកម្មករនៅក្រុមហ៊ុនស៊ីនទ្រីបានទទួលយកនូវលក្ខខណ្ឌនៃការព្រមព្រៀង និងបានត្រឡប់ទៅធ្វើការធម្មតាវិញក្តី កម្មករជាច្រើននាក់នៅតែមិនពេញចិត្តទៅនឹងអ្វី ដែលខ្លួនយល់ឃើញថាការតំឡើងប្រាក់ឈ្នួលនេះនៅមិនទាន់គ្រប់គ្រាន់នោះទេ ហើយអ្នកទាំងនោះបានបញ្ចេញនូវឆន្ទៈនឹងធ្វើកូដកម្មសារជាថ្មីទៀតនាពេលអនាគត ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។

**សេរីភាពខាងការបង្កើតសមាគម និងការចរចារអនុសញ្ញារួម**

សិទ្ធិសេរីភាពខាងការបង្កើតសមាគម និងការចរចារអនុសញ្ញារួម ត្រូវបានការពារដោយច្បាប់ជាតិ។ មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិ *"បង្កើតសហជីព និងចូលជាសមាជិកសហជីព"* ស្របពេលដែលមាត្រា ៣៧ ធានាអំពី សិទ្ធិធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី។ ម្យ៉ាងវិញទៀត ជំពូកទី ៥ នៃច្បាប់ស្តីពីការងារ ការពារសិទ្ធិក្នុងការបង្កើតអនុសញ្ញារួមដើម្បីកំណត់ពីលក្ខខណ្ឌការងារ និងទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត រួមទាំងធានាដល់កម្មករនិយោជិតចំពោះហានិភ័យសង្គម។

បន្ថែមពីលើនេះទៀត មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ចែងថា កម្ពុជាទទួលស្គាល់ និងគោរពសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទិននឹងសិទ្ធិមនុស្ស ហេតុដូច្នេះ ស.ស.ស.ម និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ត្រូវបានបញ្ចូលទៅក្នុងច្បាប់ជាតិ។ មាត្រា ២០ នៃ ស.ស.ស.ម ចែងថា *"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ និងការបង្កើតសមាគមដោយសន្តិវិធី"* នៅខណៈដែលមាត្រា ២៣ បញ្ញត្តថា *"មនុស្សគ្រប់រូប មានសិទ្ធិបង្កើត និងចូលរួមសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន"*។ មាត្រា ២២ នៃ ក.អ.ស.ព.ន ដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័នកាលពីឆ្នាំ១៩៩២ ក៏ចែងអំពីសិទ្ធិសេរីភាពជាសកលក្នុងការបង្កើតសមាគម និងចូលរួមជាសមាជិកសមាគម។ កិច្ចការពារបន្ថែមទៀតត្រូវបានផ្តល់តាមរយៈអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ("អាយឡូ") ស្តីពីសេរីភាពក្នុងការបង្កើតសមាគម និងកិច្ចការពារសិទ្ធិក្នុងការបង្កើត ឆ្នាំ១៩៤៨ និងអនុសញ្ញាស្តីពីសិទ្ធិក្នុងការបង្កើត និងការចរចារអនុសញ្ញារួម ឆ្នាំ១៩៤៩ ដែលអនុសញ្ញាទាំងពីរនេះត្រូវបានរដ្ឋាភិបាលផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩៩ ដែលបង្កើតបានជាចំណងកាតព្វកិច្ចតាមផ្លូវច្បាប់ដល់រដ្ឋាភិបាលផងដែរ។

**សេចក្តីសន្និដ្ឋាន**

ការតវ៉ារបស់កម្មករប្រមូលសំរាម ដែលបានកើតឡើងកាលពីដើមខែកុម្ភៈនេះ ប្រព្រឹត្តទៅដោយសន្តិវិធី ថ្វីបើបានបំពានទៅនឹងបម្រាមលើការប្រមូលផ្តុំគ្មានពេលកំណត់នៅកម្ពុជារបស់រដ្ឋាភិបាល។ នៅគ្រាដែលភាពអត់ធ្មត់របស់អាជ្ញាធរនៅក្នុងករណីនេះមានលក្ខណៈវិជ្ជមាន ក្រុមហ៊ុនស៊ីនទ្រី និងអាជ្ញាធរបានគំរាមកំហែងផ្ទាល់មាត់ដោយដាក់សម្ពាធលើកម្មករឲ្យទទួលយកនូវការព្រមព្រៀងមួយ ហើយប្រការនេះចង្អុលបង្ហាញថាសេរីភាពខាងការបង្កើតសមាគម សិទ្ធិរបស់សហជីព និងសិទ្ធិចរចារអនុសញ្ញារួម មិនត្រូវបានការពារឲ្យបានគ្រប់គ្រាន់នៅឡើយទេនៅកម្ពុជា។

ម.ស.ម.ក សូមជំរុញឲ្យនិយោជកទាំងឡាយ និងរដ្ឋាភិបាល ត្រូវគោរពសេរីភាពខាងការបង្កើតសមាគម និងសិទ្ធិរបស់សហជីព ដើម្បីធានាថា សកម្មភាពនៃការធ្វើកូដកម្មដោយសមូហវិធីត្រូវបានដោះស្រាយដោយសន្តិវិធី។ ជាពិសេស និយោជកត្រូវធ្វើការចរចារប្រកបដោយភាពស្មោះត្រង់ជាមួយនឹងសហជីព។ លើសពីនេះទៀត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គួរតែផ្តល់នូវការគាំទ្រដល់សហជីព ក្នុងការដោះស្រាយវិវាទបុគ្គល និងវិវាទការងាររួម។ ម.ស.ម.ក ជឿជាក់ថា ករណីនេះបង្ហាញយ៉ាងច្បាស់ថា នៅពេលដែលបណ្តាដៃគូទាំងអស់ធ្វើការរួមគ្នា ចូលរួមក្នុងកិច្ចសន្ទនា និងមានឆន្ទៈក្នុងការសម្រុះសម្រួល នោះការចរចារអនុសញ្ញារួមអាចនឹងផ្តល់នូវលទ្ធផលដែលល្អទាំងអស់គ្នា។

**សម្រាប់ព័ត៌មានលម្អិត សូមទាក់ទងលោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬតាមរយៈអ៊ីម៉ែល៖ duchpiseth@cchrcambodia.org ឬ លោកស្រី ហ្សូលីយ៉ែត រ៉ូស្សែឡូត តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១៥ ៣៥ ០៦ ២០ ឬតាមរយៈអ៊ីម៉ែល៖ julietterousselot@cchrcambodia.org**។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

BY NC SA